00572096

**Declassified to Public**
**12 April 2013**

D388

# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១០

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 22 / 07 / 2010
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 23-Jul-2010, 14:19
Kauv Keoratanak

---

# សារណារបស់ លោក អៀង សារី ជំទាស់នឹងការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់នៅ អ.វ.ត.ក

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

D388

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") សូមជំទាស់នឹងការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់នៅ អ.វ.ត.ក។ ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនឹងមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើដំណើរការនីតិវិធីនៅ អ.វ.ត.ក នាពេលខាងមុខនេះ ដោយសារតែមានបញ្ហាយុត្តាធិការជាច្រើនកើតមានឡើងនៅចំពោះមុខ អ.វ.ត.ក ដូចជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាដើម ដែលមានតែនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិប៉ុណ្ណោះ។ ការជំទាស់តវ៉ាលើយុត្តាធិការនេះ ត្រូវបានធ្វើឡើងជាចាំបាច់ ដោយហេតុថា អ.វ.ត.ក នឹងធ្វើសកម្មភាព *ហួសព្រំដែនសមត្ថកិច្ច (ultra vires) របស់ខ្លួន* ដោយការយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្តដោយផ្ទាល់។ ការជំទាស់តវ៉ានេះគឺដោយសារ ១) អ.វ.ត.ក គឺជាតុលាការជាតិ ២) គេមិនអាចយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្តនៅក្នុងតុលាការកម្ពុជាដោយផ្ទាល់បានទេ ៣) គេមិនអាចយកច្បាប់ទំនៀមទម្លាប់អន្តរជាតិមកអនុវត្តនៅ អ.វ.ត.ក បានទេ និង ៤) បើទោះបីជាបទដ្ឋានជាក់លាក់មួយចំនួននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានបំពេញ ឬមិនបានបំពេញលក្ខខណ្ឌដាច់ខាត (*jus cogens* status) ក៏ដោយ ក៏វាមិនប៉ះពាល់ដល់ការមិនអនុវត្តបទដ្ឋានជាក់លាក់ទាំងនេះនៅ អ.វ.ត.ក នោះដែរ។

## I. ភាពអាចទទួលយកបាននៃការជំទាស់តវ៉ាទៅលើយុត្តាធិការ

១. បញ្ហាយុត្តាធិការត្រូវតែលើកឡើងនៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី[១]។ វិធាន ៧៤ (៣) (ក) នៃវិធានផ្ទៃក្នុង ផ្តល់សិទ្ធិឱ្យមេធាវីការពារក្តីប្តឹងឧទ្ធរណ៍ទៅចំពោះមុខអង្គបុរេជំនុំជម្រះប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ដែលបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក។ សិទ្ធិប្តឹងឧទ្ធរណ៍នេះអាចមិនមានន័យអ្វីទេ ប្រសិនបើមេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឱ្យលើកឡើងពីបញ្ហាយុត្តាធិការនៅចំពោះមុខ ក.ស.ច.ស នោះទេ។ វិធានផ្ទៃក្នុងមិនគួរត្រូវបានបកស្រាយដោយកាត់បន្ថយការការពារដែលបានផ្តល់ឱ្យភាគីយ៉ាងច្បាស់ហើយនោះទេ។ អនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា រាល់វិមតិសង្ស័យទៅលើការបកស្រាយវិធានផ្ទៃក្នុងឱ្យបានត្រឹមត្រូវ ត្រូវតែបានជាប្រយោជន៍ដល់លោក អៀង សារី[២]។

---

[១] វិធាន ៧៤(៣)(ក) អនុញ្ញាតឱ្យភាគីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់ ក.ស.ច.ស ដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក។ មេធាវីការពារក្តីត្រូវតែមានលទ្ធភាពលើកឡើងជាមុនពីការជំទាស់តវ៉ាចំពោះយុត្តាធិការរបស់ អ.វ.ត.ក ដើម្បីអោយវិធានផ្ទៃក្នុងនេះអាចអនុវត្តក្នុងរឿងជាក់ស្តែងបាន ។

[២] *សូមមើល*មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មក្នុងឆ្នាំ ១៩៩៩។ មាត្រា ៣៨ ចែងថា៖ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។

## II. ច្បាប់ពាក់ព័ន្ធ - ច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងតុលាការជាតិ

២. ជាទូទៅ ច្បាប់អន្តរជាតិមិនបានបញ្ញត្តិ ថាតើកាតព្វកិច្ចអន្តរជាតិអាចត្រូវបានយកមកអនុវត្ត នៅក្នុងដែនសមត្ថកិច្ចច្បាប់ជាតិ[៣] បានដោយរបៀបណានោះទេ។ ក្នុងករណីដែលមិនមានកាតព្វកិច្ចជាក់លាក់នៅក្នុងសន្ធិសញ្ញា ដើម្បីកែប្រែចំណុចខ្លះនៃក្របខណ្ឌច្បាប់ផ្ទៃក្នុងរបស់រដ្ឋទេ នោះជាទូទៅ គឺវាអាស្រ័យទៅលើរដ្ឋនីមួយៗជាអ្នកសម្រេចថាត្រូវផ្តល់អានុភាពចំពោះកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនដោយរបៀបណានោះ[៤]។ រដ្ឋទាំងឡាយតែងតែប្រើប្រាស់វិធានផ្សេងៗដាក់អោយអនុវត្តច្បាប់អន្តរជាតិក្នុងតុលាការជាតិរបស់ខ្លួន អាស្រ័យថាតើរដ្ឋទាំងនោះអនុវត្តតាមទម្លាប់ឯកនិយម ឬទ្វិកនិយម។

៣. រដ្ឋដែលប្រកាន់យកប្រព័ន្ធឯកនិយម បានចាត់ទុកថា ច្បាប់អន្តរជាតិគឺជាផ្នែកមួយនៃច្បាប់ជាតិរបស់ខ្លួន។ ប៉ុន្តែ សំខាន់បំផុតនោះ គឺមានប្រព័ន្ធមួយដែលក្នុងនោះច្បាប់អន្តរជាតិអាច យកមកអនុវត្តដោយសេរីបាន[៥]។ សូម្បីតែនៅក្នុងទម្រង់ដ៏បរិសុទ្ធរបស់ខ្លួន ក៏ប្រព័ន្ធឯកនិយមមានទស្សនៈយល់ឃើញថា ច្បាប់អន្តរជាតិត្រូវមានឧត្តមភាពខ្ពស់ជាង ដែនសមត្ថកិច្ចច្បាប់ជាតិ[៦]។ អ្នករិះគន់ប្រព័ន្ធឯកនិយមត្រង់ចំណុចនេះ ដូចជា សាស្ត្រាចារ្យ Ian Brownlie បានអោយឈ្មោះប្រព័ន្ធនេះថា "វិសមានចិត្តទៅនឹងលទ្ធផលច្បាប់នៃអត្ថិភាពរបស់រដ្ឋអធិបតេយ្យ..." ។ ប្រព័ន្ធនេះបានបន្ថយច្បាប់ជាតិមានឋានៈត្រឹមតែជាអ្នកចាំទទួលអ្វីដែលមាននៅក្នុងច្បាប់អន្តរជាតិតែប៉ុណ្ណោះ"[៧]។

៤. រដ្ឋដែលប្រកាន់យកប្រព័ន្ធទ្វិកនិយម ពិចារណាទៅលើប្រព័ន្ធច្បាប់អន្តរជាតិ និងប្រព័ន្ធច្បាប់ជាតិថា

---

[៣] *សូមមើល* MARTIN DIXON, TEXTBOOK ON INTERNATIONAL LAW (សៀវភៅស្តីច្បាប់អន្តរជាតិ), 82-83 (4th ed. Blackstone Press Limited 2002) ("DIXON")។

[៤] *សូមមើល* ANTONIO CASSESE, INTERNATIONAL CRIMINAL LAW (ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ) 304-06 (Oxford University Press 2003) ("CASSESE")។

[៥] MALCOLM SHAW, INTERNATIONAL LAW (ច្បាប់អន្តរជាតិ), 122 (5th ed. Cambridge 2003) ("SHAW") ។

[៦] DIXON ត្រង់ទំព័រ៨៣។ "...អាចមានវិវាទរវាងប្រព័ន្ធពីរៈ ច្បាប់អន្តរជាតិអាចតម្រូវឱ្យមានលទ្ធផលមួយ ឯបទបញ្ញត្តិនៃច្បាប់ជាតិអាចតម្រូវឱ្យមានលទ្ធផលមួយផ្សេង។ ប្រសិនបើបញ្ហានេះកើតឡើងនៅក្នុងករណីជាក់ស្តែងណាមួយ នោះច្បាប់អន្តរជាតិមានឧត្តមភាពជាង"។

[៧] IAN BROWNLIE, PRINCIPLES OF PUBLIC INTERNATIONAL LAW (ច្បាប់សាធារណៈអន្តរជាតិ) 32, (6TH ed. Oxford 2004)។

00572099



D 388

មានដែនសមត្ថកិច្ចពីរដាច់ដោយឡែកពីគ្នា[៨]។ "វិធាននៃប្រព័ន្ធច្បាប់អន្តរជាតិ និងច្បាប់ជាតិ មានអត្ថិភាពដាច់ដោយឡែកពីគ្នា និងមិនអាចអះអាងថា ប្រព័ន្ធច្បាប់ណាមួយជះឥទ្ធិពលលើ ឬក៏ច្រានចោលប្រព័ន្ធច្បាប់មួយទៀតបានទេ[៩]។ នៅក្នុងរដ្ឋបែបនោះ ច្បាប់អន្តរជាតិមិនអាចបញ្ច្រៀតចូលទៅក្នុងដែនសមត្ថកិច្ចនៃច្បាប់ជាតិបានឡើយ ដោយមិនមានសកម្មភាពមួយចំនួនរបស់អាជ្ញាធរជាតិពាក់ព័ន្ធ ដោយជាក់ស្តែងធ្វើការបម្លែងនូវនិយាមទាំងនោះអោយទៅជាច្បាប់ជាតិ[១០]។

## ក. គោលការណ៍ទូទៅជាក់អោយអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងតុលាការជាតិ

៥. តុលាការជាតិកាន់តែមានភាពស្ទាក់ស្ទើរច្រើនឡើង ក្នុងការអនុវត្តដោយផ្ទាល់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាជាងអនុវត្តច្បាប់អន្តរជាតិដែលកើតចេញពីសន្ធិសញ្ញា ឬអនុសញ្ញានានា។ នេះគឺមួយផ្នែកដោយសារ លក្ខណៈធម្មជាតិនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមិនបានចែងជាលាយលក្ខណ៍អក្សរ ឬដោយសារតែការវិវត្តប្រែប្រួលរបស់វា[១១]។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានកំណត់និយមន័យថាជា "ទំនៀមទម្លាប់ និងគោលការណ៍ទូទៅ ដែលត្រូវបានចាត់ថ្នាក់ថាជាប្រភពនៃច្បាប់ដែលមិនមានសរសេរជាលាយលក្ខណ៍អក្សរ ហើយកម្រិតនៃភាពច្បាស់លាស់ ភាពជាក់លាក់ និងនៅក្នុងការវិភាគចុងក្រោយ គឺការធានាដែលច្បាប់នេះមានចំពោះទំនាក់ទំនងគតិយុត្តិ ជាទូទៅ មិនអាចប្រកួតប្រជែងនឹងគុណភាពដូចគ្នារបស់សន្ធិសញ្ញាអន្តរជាតិបានទាល់តែសោះ"[១២]។ តាមពិតទៅ ប្រព័ន្ធច្បាប់ជាតិអាចអនុវត្តវិធាននានានៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានតែក្នុង

---

[៨] SHAW, ទំព័រ១២២។

[៩] *ដូចជើងទំព័រខាងលើ*។

[១០] អត្ថបទរបស់ WARD N. FERDINANDUSSE ក្រោមចំណងជើងថា *ការអនុវត្តដោយផ្ទាល់នូវច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅក្នុងតុលាការជាតិ* DIRECT APPLICATION OF INTERNATIONAL CRIMINAL LAW IN NATIONAL COURTS 130 (T.M.C. Asser Press 2006) (ហៅកាត់ថា "FERDINANDUSSE")។

[១១] Simonetta Stirling-Zanda, ការពិចារណាទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅតុលាការអឺរ៉ុប រួមមានប្រទេស (បារាំង អាល្លឺម៉ង់ អ៊ីតាលី ហូឡង់ អេស្ប៉ាញ និងស្វីស) *in* 4 NON-STATE ACTORS & INT'L L. 3, 5 (2004) ("Zanda")។

[១២] Constantin Economides ទំនាក់ទំនងរវាងច្បាប់ជាតិ និងច្បាប់អន្តរជាតិ (ក្រុមប្រឹក្សាអឺរ៉ុប ១៩៩៣), ១៥។

ករណី៖ ១) ការអនុវត្តដោយផ្ទាល់ ត្រូវបានអនុញ្ញាតយ៉ាងច្បាស់លាស់ដោយរដ្ឋធម្មនុញ្ញ[១៣] ឬ ២) ការអនុវត្តដោយផ្ទាល់នូវវិធានមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ដាក់អោយអនុវត្ត ហើយវិធាននេះត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធច្បាប់ជាតិរបស់រដ្ឋនោះ[១៤]។

## ១. ការអនុវត្តតាមរយៈការអនុញ្ញាតដោយរដ្ឋធម្មនុញ្ញ

៦. សូម្បីតែមានការយោងទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងរដ្ឋធម្មនុញ្ញរបស់រដ្ឋមួយក៏ដោយ ក៏ការយោងនេះផ្ទាល់ "មិនអាចបង្កឲ្យមានការអនុវត្តដោយផ្ទាល់ជាស្វ័យប្រវត្តិបានទេគឺត្រូវយកកត្តាមួយចំនួនទៀតមកធ្វើការពិចារណាផងដែរ"[១៥]។ ការសម្រេចរបស់តុលាការទៅលើការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ត្រូវពិចារណាផងដែរ "ថាតើអ្នកធ្វើសេចក្តីព្រាងមានបំណងចង់ឲ្យបទដ្ឋានមិនមានសរសេរជាលាយលក្ខណ៍អក្សរ ដែលចោទជាបញ្ហាបែបនេះ ក្លាយទៅជាផ្នែកមួយនៃប្រព័ន្ធច្បាប់ជាតិដែរឬក៏ទេនោះ"[១៦]។

៧. លើសពីនេះទៀត សូម្បីតែរដ្ឋធម្មនុញ្ញអនុញ្ញាតឲ្យអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏គោលការណ៍ទាំងឡាយនៃរដ្ឋធម្មនុញ្ញផ្ទាល់ មិនត្រូវចំណុះឲ្យច្បាប់ទំនៀមទម្លាប់នេះទេ[១៧]។ ក្នុងន័យនេះ ការយោងទៅលើការអនុវត្តច្បាប់ព្រហ្មទណ្ឌជាតិដោយប្រទេសកាណាដា ដោយសំអាងទៅលើបទល្មើសដែលមានចែងក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC Statute) គឺជាសេចក្តីណែនាំមួយ។ ទោះបីជាការអនុវត្តនេះផ្តោតទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលស្ថិតនៅក្រោមសន្ធិសញ្ញា មិនមែនទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយក៏គោលការណ៍ទាំងនេះមានលក្ខណៈស្រដៀងគ្នាដែរ។ នៅក្នុងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលស្ថិតនៅក្រោមលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ប្រទេសកាណាដាបានពិចារណាថា ទម្រង់

---

[១៣] Zanda ទំព័រ៤។

[១៤] Gabriele Olivi, តួនាទីរបស់តុលាការជាតិក្នុងការផ្តន្ទាទោសបទល្មើសអន្តរជាតិ (*The Role of National Courts in Prosecuting International Crimes*), ទស្សនាវដ្តី 18 SRI LANKA J. INT'L L. 83, 87 (2006)។

[១៥] Zanda, ទំព័រ៤។

[១៦] *ដូចខាងលើដែរ*។

[១៧] *ដូចខាងលើដែរ*។ ទំព័រ៨។

នៃការទទួលខុសត្រូវរបស់ថ្នាក់លើដែលមានចែងក្នុងមាត្រា២៨ នៃលក្ខន្តិកៈនេះ គឺរំលោភលើរដ្ឋធម្មនុញ្ញរបស់ខ្លួន។ នេះគឺដោយសាររដ្ឋធម្មនុញ្ញប្រទេសកាណាដាបានតម្រូវថា ធាតុចេតនា (*mens rea*) នៃបទល្មើសធ្ងន់ធ្ងរមួយចំនួនត្រូវបានសំអាងទៅលើ**តេស្តលើធាតុអត្តនោម័ត** (subjective test) ចំណែកឯការផ្តន្ទាទោសចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលស្ថិតនៅក្រោមលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺគ្រាន់តែយោងទៅលើ**តេស្តលើធាតុសញ្ញានុម័ត** (objective test) តែប៉ុណ្ណោះ។ ហេតុដូច្នេះ រដ្ឋសភាប្រទេសកាណាដាបានបង្កើតបទល្មើសមួយថ្មី និងដាច់ដោយឡែកគឺ "បទល្មើសរំលោភលើការទទួលខុសត្រូវរបស់ថ្នាក់លើ" ដោយផ្អែកទៅលើ**ធាតុចេតនាជាសញ្ញានុម័តនេះ** (objective *mens rea*) ជំនួសឱ្យការអនុវត្តទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលបានរំលោភរដ្ឋធម្មនុញ្ញរបស់ខ្លួននោះ[១៨]។

## ២. ការអនុវត្តតាមរយៈច្បាប់ដាក់អោយអនុវត្ត

៨. នៅក្នុងដែនសមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គេបានលើកឡើងថា ច្បាប់ដាក់អោយអនុវត្តគឺជាការចាំបាច់។ យោងតាម Zanda ៖

> ជាទូទៅ គោលការណ៍ពីរដែលទាក់ទងគ្នាទៅវិញទៅមក គឺគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង (***nullum crimen sine lege***) និងគោលការណ៍ច្បាប់ដែលត្រូវមានភាពជាក់លាក់ (legal certainty) ត្រូវបានគេពិចារណាថា មានសារៈសំខាន់បំផុតចំពោះប្រព័ន្ធច្បាប់ ដោយសារថា គោលការណ៍ទាំងពីរនេះទប់ស្កាត់យ៉ាងមានប្រសិទ្ធភាពមិនឱ្យមានការដាក់បញ្ចូលទៅក្នុងច្បាប់ព្រហ្មទណ្ឌជាតិ នូវវិធានទំនៀមទម្លាប់ដែលមិនមានសរសេរជាលាយលក្ខណ៍អក្សរ ទោះជាតាមរយៈការស្រាយក្តី...។ អាស្រ័យហេតុនេះ ការអនុម័តច្បាប់ដាក់អោយអនុវត្ត គឺជាបុរេលក្ខខណ្ឌសកលចំពោះការអនុវត្តគោលការណ៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងប្រព័ន្ធច្បាប់ជាតិ[១៩]។

---

[១៨] *សូមមើល* របាយការណ៍ស្តីពីការរីកចម្រើន ដែលចេញផ្សាយដោយប្រទេសកាណាដា និងឧបសម្ព័ន្ធ។ ការជាប់ទាក់ទងសម្រាប់រដ្ឋសមាជិកក្រុមប្រឹក្សាអឺរ៉ុប ចំពោះការផ្តល់សច្ចាប័នទៅលើលក្ខន្តិកៈក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, Consult/ICC (2001) 11, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០១។

[១៩] Zanda, ទំព័រ៦។ (មានគូសបញ្ជាក់បន្ថែម)។

00572102



D 388

៩. ច្បាប់ដាក់អោយអនុវត្តនេះអាចបង្កើតឡើង ដោយការសំអាងដ៏ស្រួចស្រាវទៅលើវិធានច្បាប់ទំនៀមទម្លាប់មួយចំនួន ឬ ដោយការបង្កើតអោយទៅជាច្បាប់ព្រហ្មទណ្ឌជាតិ[២០]។ ការសំអាងដ៏មុតមាំទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌជាតិនេះ គឺជាគំរូដែលបានប្រើប្រាស់ដោយប្រទេសកាណាដា នៅក្នុងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ឆ្នាំ២000 របស់ខ្លួន[២១]។ ច្បាប់នេះចែងថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ពីជាបទល្មើសដែលអាចចោទប្រកាន់បាន[២២] និងគ្រាន់តែយោងទៅលើវិធាននៃច្បាប់អន្តរជាតិ សម្រាប់និយមន័យរបស់ច្បាប់នេះតែប៉ុណ្ណោះ[២៣]។ ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយការបង្កើតអោយទៅជាច្បាប់ព្រហ្មទណ្ឌជាតិនេះ គឺមានន័យថា ជាការអនុម័តច្បាប់ជាតិបែបស្វ័យយ័ត ដែលមានអត្ថន័យដូចគ្នាទៅនឹងច្បាប់អន្តរជាតិដែរ ប៉ុន្តែ មិនយោងទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលជាមូលដ្ឋាននោះទេ[២៤]។

## ខ. ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយលក្ខណៈប្រៀបធៀប

### ១. ប្រព័ន្ធទ្វិកនិយម

១០. ប្រព័ន្ធទ្វិកនិយមមានវិធីលាយឡំគ្នាមួយ នៅក្នុងការសម្រេចទៅលើការអនុវត្តច្បាប់ទំនៀមទម្លាប់

---

[២០] Helmut Kreicker, *National Prosecution of Genocide from a Comparative Perspective* (ការផ្តន្ទាទោសទៅលើអំពើប្រល័យពូជសាសន៍ដោយតុលាការជាតិ ពីទស្សនទានបែបប្រៀបធៀប) 5 INT'L CRIM. L. REV. 313 (2005)។

[២១] ច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងច្បាប់ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម ឆ្នាំ២000 (c. 24) (បានសម្រេចយល់ព្រមនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២000)។

[២២] *ដូចខាងលើដែរ*, § 4(1)(a).។

[២៣] ដូចខាងលើ, ផ្នែក៤(៣) ចែងពីអំពើប្រល័យពូជសាសន៍ថា "ជាអំពើ ឬការខកខាន ដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមមនុស្សដែលអាចកំណត់អត្តសញ្ញាណបាន នៅក្នុងអំឡុងពេល និងនៅទីកន្លែងដែលប្រព្រឹត្តអំពើនោះ បង្កើតបានជាអំពើប្រល័យពូជសាសន៍ ដោយអនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់អនុសញ្ញាអន្តរជាតិ ឬដោយសារតែវាមានលក្ខណៈជាអំពើល្មើសព្រហ្មទណ្ឌ ដោយអនុលោមតាមគោលការណ៍ទូទៅនៃច្បាប់ ដែលបានទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ ទោះបីថាវាបង្កើតបាន ឬមិនអាចបង្កើតបានជាការរំលោភបំពានច្បាប់ជាធរមានឬក៏អត់ក៏ដោយ នៅក្នុងអំឡុងពេល និងនៅទីកន្លែងដែលអំពើនោះត្រូវបានប្រព្រឹត្ត។

[២៤] Kreicker, ទំព័រ៣២៣។

អន្តរជាតិដោយផ្ទាល់។ មានការងាកចេញឆ្ងាយពីការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់នៅក្នុងប្រទេសអង់គ្លេស និងប្រទេសវែលស៍ (Wales) ទោះមានវិធានទូទៅកំណត់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងទៅក្នុងច្បាប់ខំមិនឡូក្លី (Common Law)[២៥]។ នៅក្នុងរឿងក្ដីរបស់ *Pinochet*[២៦] ទស្សនៈភាគច្រើនបានលើកឡើងថា ការធ្វើទារុណកម្មដែលជាបទល្មើសក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនបានយកមកអនុវត្តនៅក្នុងប្រទេសអង់គ្លេសឡើយ រហូតទាល់តែវាត្រូវបានយកមកចែងក្នុងច្បាប់ស្ដីពីយុត្តិធម៌ព្រហ្មទណ្ឌ ឆ្នាំ១៩៨៨។ ចៅក្រម **Hope** បានប្រកាសថា "មុននឹងការចូលជាធរមាននៃផ្នែក១៣៤ នៃច្បាប់ស្ដីពីយុត្តិធម៌ព្រហ្មទណ្ឌ ឆ្នាំ១៩៨៨...មិនមានមូលដ្ឋានដែល [*Pinochet*] អាចត្រូវបានកាត់សេចក្ដីក្រោយុត្តាធិការនៅក្នុងប្រទេសនេះទេ"[២៧] ដែលជាហេតុនាំឲ្យមានការបដិសេធចំពោះការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់នៅក្នុងតុលាការនានានៅប្រទេសអង់គ្លេស និងប្រទេសវែលស៍។

១១. ថ្មីៗនេះទៀត សេចក្ដីសម្រេចរបស់តុលាការជាន់ខ្ពស់ ក្នុងរឿងក្ដី *R* តទល់នឹង *Jones*[២៨] បានដោះស្រាយពីការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងប្រទេសអង់គ្លេស និងប្រទេសវែលស៍។ តុលាការជាន់ខ្ពស់នេះបានធ្វើការញែកពីគ្នារវាង ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាក់ទងនឹងសិទ្ធិ និងករណីយកិច្ចក្នុងច្បាប់រដ្ឋប្បវេណី និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលទាក់ទងនឹងសិទ្ធិ និងករណីយកិច្ចក្នុងច្បាប់រដ្ឋប្បវេណីអាចត្រូវបានយកមកអនុវត្តដោយផ្ទាល់បាន តែច្បាប់ទំនៀមទម្លាប់អន្តរជាតិទាក់ទងនឹង

---

[២៥] *សូមមើល* ក្រុមហ៊ុនសាជីវកម្ម *Trendtex (Trendtex Trading Corp)* តទល់នឹង *Central Bank of Nigeria* ធនាគារកណ្ដាលនៃប្រទេសនីហ្សេរីយ៉ា [១៩៧៧] QB 526, ទំព័រ៥៥៣។ សូមកត់សម្គាល់ថា ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់ក្នុងរឿងក្ដីនេះ គឺជាប់ពាក់ព័ន្ធនឹងវិវាទពាណិជ្ជកម្ម មិនមែនការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ។

[២៦] រឿងក្ដី *R.* តទល់នឹង *Bow Street Metropolitan Stipendiary Magistrate & Others, ex parte Pinochet Ugarte (No 3)*, ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩, [2000] 1 AC 147 ("*Pinochet*")។

[២៧] *ដូចខាងលើដែរ*, ទំព័រ២៣៧។

[២៨] *R v. Jones* [2006] UKHL 16.

ឧក្រិដ្ឋកម្មអន្តរជាតិមិនអាចយកមកអនុវត្តដោយផ្ទាល់បានទេ[២៩]។ មូលហេតុសំខាន់មួយសម្រាប់ការបដិសេធច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានលើកឡើងដោយចៅក្រម **Hoffman** ដែលបានប្រកាសថា "តាមការយល់ឃើញរបស់ខ្ញុំ បទល្មើសជាតិថ្មីទាំងនេះគួរត្រូវបានយកមកពិភាក្សាដេញដោលនៅក្នុងរដ្ឋសភា កំណត់និយមន័យក្នុងច្បាប់ និងចូលជាធរមានតាមកាលបរិច្ឆេទមួយដែលបានកំណត់។ បទល្មើសទាំងនេះមិនគួរលួចចូលទៅមានអត្ថិភាពដោយសារតែលទ្ធផលនៃមតិភាគច្រើនរបស់អន្តរជាតិ ដែលមានតែស្ថាប័ននីតិប្រតិបត្តិរបស់ប្រទេសនេះគឺជាភាគីនោះទេ"[៣០]។ ចៅក្រម **Bingham** បានប្រកាសថា ទោះបីជាឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចបញ្ចូលទៅក្នុងច្បាប់ជាតិបានក៏ដោយ ក៏ការដាក់បញ្ចូលនេះត្រូវធ្វើឡើងតាមរយៈច្បាប់ដាក់អោយអនុវត្ត "ព្រោះវាអាចជាការផ្គាំផ្គងមួយ ប្រសិនបើស្ថាប័ននីតិប្រតិបត្តិធ្វើវិសោធនកម្មឡើង ឬកែប្រែច្បាប់ព្រហ្មទណ្ឌ តាមមធ្យោបាយដោយព្រមព្រៀងជាមួយរដ្ឋដទៃទៀត ដែលនាំឱ្យមានផលវិបាកប៉ះពាល់ដល់សេរីភាពបុគ្គល និងសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិឯកជន...។ ពេលនេះ អំណាចបង្កើតបទល្មើសគួរតែត្រូវបានប្រគល់ផ្ដាច់មុខទៅឱ្យរដ្ឋសភា យោងតាមច្បាប់[៣១]។

១២. នៅក្នុងប្រទេសអូស្ត្រាលីមិនមាន "ប្បញ្ញត្តិរដ្ឋធម្មនុញ្ញ ឬប្បញ្ញត្តិច្បាប់ដែលកំណត់អំពីមធ្យោបាយផ្សេងៗឱ្យតុលាការស្វែងរក និងអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ"[៣២]។ នៅក្នុងរឿងក្ដីរវាង *Nulyarimma* តទល់នឹង *Thompson* តុលាការជាន់ខ្ពស់ប្រទេសអូស្ត្រាលីបានបដិសេធមិនឱ្យ

---

[២៩] *ដូចខាងលើដែរ*, កថាខណ្ឌ២៣, *quoting* SIR FRANKLIN BERMAN, ASSERTING JURISDICTION: INTERNATIONAL AND EUROPEAN LEGAL PERSPECTIVES [ការដកស្រង់សំដីលោក FRANKLIN BERMAN, ការអះអាងអំពីយុត្តាធិការ៖ ទស្សនទានទៅលើច្បាប់អន្តរជាតិ និងច្បាប់អឺរ៉ុប], 11 (M. Evans and S. Konstantinidis ed., Hart Publishing Ltd. 2003)។

[៣០] *ដូចខាងលើដែរ*, កថាខណ្ឌ៦២។

[៣១] ដូចខាងលើដែរ, កថាខណ្ឌ២៣, *quoting* SIR FRANKLIN BERMAN, ASSERTING JURISDICTION: INTERNATIONAL AND EUROPEAN LEGAL PERSPECTIVES [ការដកស្រង់សំដីលោក FRANKLIN BERMAN, ការអះអាងអំពីយុត្តាធិការ៖ ទស្សនទានទៅលើច្បាប់អន្តរជាតិ និងច្បាប់អឺរ៉ុប], 11 (M. Evans and S. Konstantinidis ed., Hart Publishing Ltd. 2003)។

[៣២] Henry Burmester QC, *The Determination of Customary International Law in Australian Courts* [ការពិចារណាទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងប្រទេសអូស្ត្រាលី], 4 NON-STATE ACTORS & INT'L L. 39, 40 (2004)។

D 388

មានការអនុវត្តដោយផ្ទាល់នូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[៣៣]។ នៅក្នុងរឿងក្តីរវាង *Buzzacottl* តទល់នឹង *Hil* ចៅក្រម Wilcox បានពន្យល់ពីបញ្ហាខ្លះៗដែលកើតចេញពីការធ្វើបែបនោះ ដោយការលើកឡើងថា៖

> ក្នុងករណីដែលមានការប្រព្រឹត្តអំពើព្រហ្មទណ្ឌធ្ងន់ធ្ងរ នោះតម្រូវឲ្យមានច្បាប់ជាមូលដ្ឋាន។ តើតុលាការមួយណាដែលមានយុត្តាធិការជំនុំជម្រះជនជាប់ចោទ? តើនីតិវិធីអ្វីដែលគ្របដណ្តប់ទៅលើការជំនុំជម្រះក្តីនោះ? តើការផ្តន្ទាទោសបែបណាដែលអាចយកមកអនុវត្តបាន។ ត្រូវយកបញ្ហាទាំងអស់នេះមកដោះស្រាយជាមុនសិន មុននឹងយកបុគ្គលម្នាក់មកធ្វើការជំនុំជម្រះក្តីទៅលើបទល្មើសមួយដែលគួរឲ្យញញើតដូចជា អំពើប្រល័យពូជសាសន៍នេះ[៣៤]។

១៣. សហរដ្ឋអាមេរិកក៏មិនបានពិចារណាថា ខ្លួនជាប់កាតព្វកិច្ចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងតុលាការជាតិដោយផ្ទាល់នោះដែរ "ច្បាប់របស់សហរដ្ឋអាមេរិកមិនស្ថិតនៅក្រោម ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬត្រូវតែជារណបចំពោះច្បាប់អន្តរជាតិដែលមានប្រភពពីសន្ធិសញ្ញានោះទេ តែផ្ទុយទៅវិញ ច្បាប់អាមេរិចអាចមានទំនាស់ជាមួយច្បាប់ទាំងពីរ"[៣៥]។ នៅក្នុងសវនាការអំពីការទទួលស្គាល់ (Confirmation Hearing) ប្រធានតុលាការកំពូលសហរដ្ឋអាមេរិក លោកចៅក្រម **Roberts** បានបដិសេធចំពោះការអនុវត្តច្បាប់អន្តរជាតិនៅក្នុងតុលាការអាមេរិក ដែលជាការប្រើប្រាស់ច្បាប់អន្តរជាតិ ដើម្បីកំណត់អត្ថន័យនៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកថាជា "ការប្រើប្រាស់យុត្តិសាស្ត្រខុស គឺមិនមែនជាការប្រើប្រាស់យុត្តិសាស្ត្រដែលត្រឹមត្រូវនោះទេ"[៣៦]។

## ២. ប្រព័ន្ធឯកនិយម

១៤. ការពិនិត្យដោយប្រៀបធៀបចំពោះប្រព័ន្ធឯកនិយមបង្ហាញថា ដោយមិនមានច្បាប់ដាក់អោយអនុវត្ត នោះប្រព័ន្ធទាំងនេះបានបដិសេធមិនអនុវត្តដោយផ្ទាល់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុង

---

៣៣ រឿងក្តីរវាង *Nulyarimma តទល់នឹង Thompson* (1999) 96 FCR 153។

៣៤ រឿងក្តីរវាង *Buzzacott តទល់នឹង Hill* [1999] FCA 1192; (1999) 165 ALR 621, at 630។

៣៥ រឿងក្តីរវាង *U.S. តទល់នឹង Yousef*, 327 F.3d 56, 91 (2nd Cir. 2003)។

៣៦ Justice John Roberts Confirmation Hearings, 13 September 2005 (Day 2), transcript *available at*: http://www.washingtonpost.com/wp-dyn/content/article/2005/09/13/AR2005091301210.html

តុលាការរបស់ខ្លួននោះទេ។ នៅប្រទេសបារាំង មានការលើកឡើងដដែលៗថា គេមិនអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់បានទេ។ នៅក្នុងរឿងក្តីរវាង អ្នកយកព័ត៌មានគ្មានព្រំដែន (***Reporters sans Frontières***) តទល់នឹង ***Mille Collines***[៣៧] សាលាឧទ្ធរណ៍ក្រុងប៉ារីសប្រទេសបារាំងបានលើកឡើងថា ខ្លួនមិនមានយុត្តាធិការទៅលើបទល្មើសអន្តរជាតិផ្សេងដែលបានប្រព្រឹត្តនៅក្រៅប្រទេស ដោយជនបរទេសនោះទេ ដោយបញ្ជាក់ថា៖

> ក្នុងករណីដែលមិនមានបទប្បញ្ញត្តិច្បាប់ជាតិទេ នោះទំនៀមទម្លាប់អន្តរជាតិមិនមានអានុភាពពង្រីកយុត្តាធិការឲ្យហួសដែនសមត្ថកិច្ច របស់តុលាការប្រទេសបារាំងបានឡើយ។ ក្នុងន័យនេះ មានតែប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទេ ទើបអាចយកមកអនុវត្តនៅក្រោមប្រព័ន្ធច្បាប់ជាតិបាន ដោយហេតុថាសន្ធិសញ្ញាទាំងនោះត្រូវបានអនុម័ត ឬផ្តល់សច្ចាប័នយ៉ាងត្រឹមត្រូវដោយប្រទេសបារាំង និងយោងតាមខ្លឹមសាររបស់វា ប្បញ្ញត្តិនៃសន្ធិសញ្ញាបែបនេះបង្កើតអោយមានអានុភាពផ្ទាល់[៣៨]។

១៥. នៅក្នុងរឿងក្តី *Aussaresses*[៣៩] តុលាការកំពូល (ឬ សាលាឧក្រិដ្ឋនិច្ឆ័យ Court de Cassation) ក៏មានទស្សនៈស្រដៀងគ្នានេះដែរ និងបានប្រកាសថា "វិធានទំនៀមទម្លាប់អន្តរជាតិមិនអាចយកមកជំនួស ខណៈដែលមិនមានប្បញ្ញត្តិចែងផ្តន្ទាទោសអំពើទាំងឡាយដែលប្តឹងបរិហារដោយដើមបណ្តឹងរដ្ឋប្បវេណី ***(civil petitioner/partie civile)*** ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ"[៤០]។ ការបដិសេធបែបប្រហែលជាសំអាងទៅលើបញ្ហាដែលថា ប្រទេសបារាំង ក៏ដូចជាប្រទេសកម្ពុជា[៤១] យោងតែទៅលើសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ នៅក្នុងរដ្ឋធម្មនុញ្ញ

---

៣៧ Olivi ត្រង់ទំព័រ ៨៧ *ដោយដកស្រង់* រឿងក្តីរវាង *Reporters sans Frontières* ***តទល់នឹង*** *Mille Collines,* របស់សាលាឧទ្ធរណ៍ទីក្រុងប៉ារីស (Cour d'appel de Paris) ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

៣៨ *ដូចខាងលើដែរ*, ទំព័រ ៥៨-៥១។

៣៩ តុលាការកំពូល (Court of Cassation), រឿងក្តី *Aussaresses,* សភាព្រហ្មទណ្ឌ (Chambre Criminelle) ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០០៣, *Bull. crim.* 2003 n° 122 ទំព័រ ៤៦៥ ។

៤០ *សូមមើល* Juliette Lelieur-Fischer, *Prosecuting the Crimes against Humanity Committed during the Algerian War [ការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងសង្គ្រាមនៅប្រទេសអាល់ហ្សេរី: an Impossible Endeavour [ការខិតខំប្រឹងប្រែងដែលមិនអាចធ្វើទៅបាន]?*, 2 J. INT'L CRIM. JUST. 236 (2004), ដកស្រង់ចេញពីសាលដីកាតុលាការកំពូល [*Cour de Cassation*] ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៣។

៤១ *សូមមើល* RAOUL M. JENNAR, រដ្ឋធម្មនុញ្ញកម្ពុជា (១៩៥៣-១៩៩៣) (White Lotus, 1995) ("JENNAR")។

របស់ខ្លួន ជាជាង ច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

១៦. វិធីសាស្ត្រស្រដៀងគ្នា ក្នុងការបដិសេធការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់ ត្រូវបានអនុវត្តតាមដោយតុលាការកំពូលប្រទេសហូឡង់ នៅក្នុងរឿងក្តី ***Bouterse***។ ក្នុងរឿងក្តីនេះ តុលាការកំពូលប្រទេសហូឡង់ បានសម្រេចជំទាស់ទៅនឹងការអនុវត្តច្បាប់ទំនៀមទម្លាប់ដោយផ្ទាល់ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោសបទល្មើសអន្តរជាតិ នៅក្នុងតុលាការជាតិ។ តុលាការកំពូលនេះបានសម្រេចថា ការអនុវត្តដោយផ្ទាល់អាចបង្កការគំរាមកំហែងដល់គោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង (***nullum crimen sine lege***)[៤២]។ វិធីសាស្ត្រស្រដៀងគ្នាក្នុងការបដិសេធការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់នេះ ក៏អាចត្រូវបានរកឃើញផងដែរនៅក្នុងយុត្តិសាស្ត្ររបស់ប្រទេសស្វីស[៤៣] និងអាឡឺម៉ង់[៤៤]។

## III. ទឡ្ហីករណ៍

### ក. អវតក ជាតុលាការជាតិ

១៧. ការចរចារដើម្បីបង្កើត អ.វ.ត.ក បានផ្តល់លទ្ធផលឱ្យមានការបង្កើតអង្គជំនុំជម្រះតុលាការជាតិនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ដោយមានជំនួយថវិកា និងធនធានផ្សេងៗពីអន្តរជាតិ។ ទាំងរដ្ឋាភិបាលកម្ពុជា ទាំងអង្គការសហប្រជាជាតិ (“UN”) មិនមានគោលបំណងបង្កើត អ.វ.ត.ក ជាតុលាការអន្តរជាតិនោះទេ។ ឯកសារគោលទាំងអស់របស់ អ.វ.ត.ក មិនបានបញ្ជាក់បញ្ហានេះឱ្យបានច្បាស់លាស់ ឬមិនច្បាស់លាស់នោះទេ។ ក្នុងអំឡុងនៃការចរចាររវាងរដ្ឋាភិបាលកម្ពុជា និង UN សហគមន៍អន្តរជាតិបានស្នើឱ្យមានការបង្កើតតុលាការអន្តរជាតិមួយ។ ប៉ុន្តែ គំនិតនេះត្រូវបានរដ្ឋាភិបាលកម្ពុជាច្រានចោលយ៉ាងច្បាស់ក្រឡែត[៤៥]។ <u>សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលជានាយករដ្ឋមន្ត្រី បានទាមទារថា វិសាលភាពនៃការចូលរួមរបស់ UN ត្រូវមានកម្រិតត្រឹម “ការផ្តល់អ្នកជំនាញដើម្បីជួយកម្ពុជា ក្នុងការធ្វើសេចក្តីព្រាងច្បាប់ ដែលអាចនាំឱ្យមានការបង្កើត</u>

---

[៤២] FERDINANDUSSE, ទំព័រ ៦៩ ។

[៤៣] *ដូចខាងលើដែរ*, ទំព័រ ៤០-៤១។

[៤៤] *ដូចខាងលើដែរ*, ទំព័រ ៤០។

[៤៥] របាយការណ៍របស់លោកអគ្គលេខាធិការ អ.ស.ប ស្តីពីការកាត់សេចក្តីខ្មែរក្រហម, ឯកសារអង្គការសហប្រជាជាតិលេខ A/57/769, ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ៦។

តុលាការជាតិកម្ពុជាពិសេសមួយ ដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហម និងដែលអាចជួយផ្តល់ចៅក្រម និងព្រះរាជអាជ្ញាបរទេស ដើម្បីចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការនេះ"[៤៦]។ ដូច្នេះ មិនមានអ្វីដែលគួរឱ្យងឿងឆ្ងល់នោះទេថា រដ្ឋាភិបាលកម្ពុជា និង UN បានចរចារគ្នា និងបានឈានដល់ការព្រមព្រៀងគ្នាមួយ ក្នុងការបង្កើតមាន អ.វ.ត.ក ជាតុលាការជាតិនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់[៤៧]។

១៨. ដើម្បីជាការឆ្លុះបញ្ចាំងពីគោលបំណង និងលទ្ធផលនៃការចរចារ កិច្ចព្រមព្រៀងចែងថា៖

**ដោយហេតុថា** នៅមុនពេលចរចារលើកិច្ចព្រមព្រៀងនេះ មានការរីកចម្រើនជាច្រើនធ្វើឡើងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (...) និងរាជរដ្ឋាភិបាលកម្ពុជា ឈានទៅរកការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ... ដោយមានជំនួយពីអន្តរជាតិ។

**ដោយហេតុថា** យោងតាមសេចក្តីសម្រេចចិត្តលេខ ៥៧/២២៨ មហាសន្និបាត...ហើយបានស្នើសុំលោកអគ្គលេខាធិការឱ្យបន្តការចរចារដោយពុំមានការពន្យារពេល ដើម្បីសម្រេចកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាល ដោយឈរលើការចរចារពីពេលមុន...[៤៨]។

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចែងថា "ត្រូវបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ

---

[៤៦] *ដូចខាងលើដែរ*, កថាខណ្ឌ៧។

[៤៧] *ដូចខាងលើដែរ,* កថាខណ្ឌ១០។ លោកអគ្គលេខាធិការបានថ្លែងថា "នៅក្នុងកថាខណ្ឌ១ នៃសេចក្តីសម្រេចចិត្តលេខ ៥៧/២២៨ មហាសន្និបាតបានចាត់ជាពិសេសឱ្យរូបខ្ញុំចរចារដើម្បីសម្រេចឱ្យបានកិច្ចព្រមព្រៀងមួយដែលស្របជាមួយនឹងបញ្ញត្តិរបស់សេចក្តីសម្រេចចិត្តនេះ។ ខ្ញុំយល់ឃើញថា ដើម្បីឱ្យស្របទៅនឹងលក្ខខណ្ឌរបស់សេចក្តីសម្រេចិត្តនេះ កិច្ចព្រមព្រៀងណាមួយរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖ (ក) កិច្ចព្រមព្រៀងនោះត្រូវគោរព និងផ្តល់ប្រសិទ្ធភាពសំខាន់ចំពោះគោលការណ៍ ដែលថាអង្គជំនុំជម្រះវិសាមញ្ញគឺជាតុលាការថ្នាក់ជាតិ នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ដែលត្រូវបានបង្កើតឡើង និងប្រតិបត្តិដោយមានជំនួយពីអន្តរជាតិ..."។ *សូមមើលផងដែរ ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣១ ដែលរូបគាត់បានពិភាក្សាអំពីចរិតលក្ខណៈរបស់ អ.វ.ត.ក នៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនោះថា៖ "ដូចគ្នានឹងស្ថាប័នច្បាប់ដទៃទៀតដែរ ចរិតលក្ខណៈផ្នែកច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវកំណត់ដោយលិខិតុបករណ៍ដែលបង្កើតតុលាការទាំងនេះ។ ស្របគ្នានឹងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ អង្គជំនុំជម្រះវិសាមញ្ញត្រូវបង្កើតឡើងដោយច្បាប់ជាតិរបស់ប្រទេសកម្ពុជា។ ហេតុដូច្នេះ អង្គជំនុំជម្រះវិសាមញ្ញ គឺជាតុលាការជាតិរបស់កម្ពុជា ដែលត្រូវបានបង្កើតឡើងក្នុងរចនាសម្ព័ន្ធតុលាការរបស់ប្រទេសនេះ"។ (គូសបញ្ជាក់បន្ថែម)។

[៤៨] បុព្វកថានៃកិច្ចព្រមព្រៀង។

នៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់..."[៤៩]។

១៩. នៅក្នុងការសម្រេច ថាតើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញស្របជាមួយរដ្ឋធម្មនុញ្ញកម្ពុជាដែរឬទេនោះ កង្វល់របស់ក្រុមប្រឹក្សាធម្មនុញ្ញទាក់ទងទៅនឹងឋានៈរបស់ អ.វ.ត.ក គឺមានលក្ខណៈច្បាស់លាស់ហើយ។ ក្រុមប្រឹក្សាធម្មនុញ្ញបានលើកឡើងថា "ដើម្បីបំរើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ទាំងភាគីខ្មែរ ទាំងភាគីមកពីអង្គការសហប្រជាជាតិ សុទ្ធតែត្រូវបានតែងតាំងឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នកំពូលជាតិខ្មែរសុទ្ធសាធ សូម្បីតែប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលក៏ត្រូវបានតែងតាំងដោយអាជ្ញាធរកម្ពុជាដែរ។ ក្នុងន័យនេះ អង្គការសហប្រជាជាតិមានភារកិច្ចត្រឹមស្នើបញ្ជីបេក្ខជនតែប៉ុណ្ណោះ ហើយគ្មានសិទ្ធិសម្រេចទេ"[៥០]។ ក្រុមប្រឹក្សាធម្មនុញ្ញបានបន្តលើកឡើងថែមទៀតថា "ការយកប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ និងការរើសយករាជធានីភ្នំពេញជាទីតាំងដំណើរការ ជាការគាំពារថ្មីមួយទៀតដល់អធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា"[៥១]។

២០. គេហទំព័ររបស់ អ.វ.ត.ក និងរបស់ជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះខ្មែរក្រហម ("UNAKRT") ក៏បានពន្យល់ដល់សាធារណៈជនថា អ.វ.ត.ក គឺជាតុលាការជាតិកម្ពុជា។ គេហទំព័ររបស់ អ.វ.ត.ក លើកឡើងថា "រដ្ឋាភិបាលកម្ពុជាបានទទូចស្នើសុំថា ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ ការជំនុំជម្រះក្តីត្រូវប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា ដោយការប្រើប្រាស់ចៅក្រម និងបុគ្គលិកកម្ពុជា រួមជាមួយនឹងចៅក្រម និងបុគ្គលិកអន្តរជាតិ។ ដោយសារតែប្រព័ន្ធច្បាប់កម្ពុជានៅទន់ខ្សោយ និងដោយសារតែឧក្រិដ្ឋកម្មទាំងនេះមានចរិតលក្ខណៈជាអន្តរជាតិ កម្ពុជាបានអញ្ជើញឱ្យមានការចូលរួមពីអន្តរជាតិ ដើម្បីឱ្យឆ្លើយតបទៅនឹងបទដ្ឋានយុត្តិធម៌អន្តរជាតិ"[៥២]។ គេហទំព័ររបស់ UNAKRT លើកឡើងថា "UNAKRT ផ្តល់ជំនួយបច្ចេកទេសដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ អ.វ.ត.ក គឺជាតុលាការជាតិ ដែលត្រូវបានជួយគាំទ្រដោយបុគ្គលិកអន្តរជាតិ និងត្រូវបានបង្កើតឡើងស្របតាម

---

[៤៩] មាត្រា ២ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក (គូសបញ្ជាក់បន្ថែម) ។

[៥០] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៤០/០០២/២០០១ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ទំព័រ៣ (បកប្រែក្រៅផ្លូវការ, គូសបញ្ជាក់បន្ថែម)។

[៥១] *ដូចខាងលើដែរ*, ត្រង់ទំព័រ៤ (បកប្រែក្រៅផ្លូវការ, មានបញ្ជាក់បន្ថែម)។

[៥២] អាចរកបាននៅលើគេហទំព័រ http://www.eccc.gov.kh/english/about_eccc.aspx។

ច្បាប់កម្ពុជា"[៥៣]។

២១. អង្គបុរេជំនុំជម្រះបានលើកឡើងថា "<u>សម្រាប់គោលបំណងក្នុងការអនុវត្តជាក់ស្តែង និងតាមផ្លូវច្បាប់</u> អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យ ហើយប្រតិបត្តិការរបស់ខ្លួនក៏ត្រូវឯករាជ្យផងដែរ <u>នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា</u>..."[៥៤]។ ទោះជាអង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") បានលើកឡើងថា អ.វ.ត.ក គឺជា "តុលាការពិសេសដែលមានចរិតលក្ខណៈអន្តរជាតិ"[៥៥] <u>អង្គបុរេជំនុំជម្រះមិនបានយល់ស្របតាមជំហរនេះទេ</u>។ ប្រសិនបើ អ.វ.ត.ក ពិតជាតុលាការអន្តរជាតិ (ឬ "មានចរិតលក្ខណៈអន្តរជាតិមែន" ឧបមាថា សម្មតិនាមដែលបានដាក់ឱ្យដោយ ក.ស.ព មានតម្លៃដោយប្រការណាមួយ) ដោយ អ.វ.ត.ក អាចដាក់បញ្ចូលច្បាប់ និងទម្រង់នៃការទទួលខុសត្រូវទាំងឡាយដែលផ្ទុយ និងរំលោភបំពានរដ្ឋធម្មនុញ្ញកម្ពុជា ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ចុះហេតុដូចម្តេចបានជាចៅក្រមរបស់ អ.វ.ត.ក មិនមានសមត្ថភាពដោះស្រាយបញ្ហាអំពើពុករលួយនៅ អ.វ.ត.ក? សេចក្តីសម្រេចរបស់ចៅក្រម អ.វ.ត.ក យល់ស្របតាមរដ្ឋាភិបាលកម្ពុជា ដោយបដិសេធមិនដោះស្រាយអំពើពុករលួយនេះ[៥៦]

---

[៥៣] អាចរកបាននៅលើគេហទំព័រ http://www.unakrt-online.org/01_home.htm (គូសបញ្ជាក់បន្ថែម)។

[៥៤] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧- អ.វ.ត.ក-ក.ស.ច.ស (អបជ០១), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ C5/45 ERN: 00154284-00154302 ("សាលដីកាករណីឃុំខ្លួនឌុចបណ្តោះអាសន្ន") កថាខណ្ឌ១៩ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧- អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ៣៥) សាលដីកាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/14/15, ERN: 00486521-00486589 ("សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួម") កថាខណ្ឌ៤៧។

[៥៥] "<u>សហព្រះរាជអាជ្ញាបានជូនសំអាងថា</u> ___កត្តាមួយចំនួនដែលបានសង្ខេបនៅក្នុងរបាយការណ៍បង្ហាញពីឯករាជ្យភាពនេះដែលធ្វើឱ្យ អ.វ.ត.ក ក្លាយជា "សាលាក្តីពិសេស និងមានចរិកលក្ខណៈអន្តរជាតិ""។ សាលដីកាករណីឃុំខ្លួនឌុចបណ្តោះអាសន្ន កថាខណ្ឌ១៩ (គូសបញ្ជាក់បន្ថែម)។

[៥៦] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ២០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់ នួន ជា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ឯកសារ D158/5/3/15, ERN: 00366747-00366761 កថាខណ្ឌ២៩ "អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ករណីនេះកំពុងស្ថិតនៅចំពោះមុខស្ថាប័នសមស្រប គឺរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ"។

បញ្ជាក់ថា ពួកគាត់មានទស្សនៈយល់ឃើញថា អ.វ.ត.ក ពិតជាតុលាការជាតិមែន។ ពិតមែនហើយ តុលាការអន្តរជាតិមិនអចិន្ត្រៃយ៍ ឬ តុលាការដែលមានចរិតលក្ខណៈអន្តរជាតិ នឹងមិនសម្រេចចិត្ត ធ្វើមិនដឹងមិនឮដោយចេតនា ប្រសិនបើមិនដល់ថ្នាក់បណ្តែតបណ្តោយ (ការយល់ឃើញដែលជាបញ្ហ័យដោយសារតែការមិនបានធ្វើសកម្មភាព) ចំពោះការប្រព្រឹត្តអំពើពុករលួយ ដែលគេបានអះអាងថាកើតមាននៅ អ.វ.ត.ក នោះទេ[៥៧]។

## ខ. ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចអនុវត្ត នៅក្នុងតុលាការកម្ពុជា ដោយផ្ទាល់បានទេ

---

[៥៧] *សូមមើល រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើលើកទី១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ឯកសារ D158, ERN: 002294816-00294830។ *សូមមើលសំណុំរឿង លោក នួន ជា* លេខ០០២/១៩-០៩-២០០៧- អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ ឯកសារ D158/5, ERN: 00294885-00294888។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧- អ.វ.ត.ក-ក.ស.ច.ស ញត្តិរបស់លោក អៀង សារី សុំចូលរួម និងទទួលយកតាមសំណើសុំអោយបំពេញកិច្ចស៊ើបសួរទី១១ របស់ នួន ជា ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ឯកសារ D258/2, ERN: 00294872-00294873។ *សូមមើល រឿងក្តី នួន ជា* សំណុំរឿងលេខ០០២/១៩-០៩-២០០៧- អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ២១) បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំលើកទី១១ ស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D158/5/1/1, ERN: 00323238-00323255។ *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧- អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ២០) បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ អំពីការចោទប្រកាន់ជាហូរហែរអំពីអំពើពុករលួយ និងសំណើសុំចាត់ការសវនាការដេញដោលផ្ទាល់មាត់ឱ្យឆាប់រហ័ស ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D158/5/3/1, ERN: 00323171-00323193។ *រឿងក្តី នួន ជា* សំណុំរឿងលេខ០០២/១៩-០៩-២០០៧- អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ២១) សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើលើកទីដប់មួយរបស់ជនត្រូវចោទ សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D158/5/1/15, ERN: 00364033-00364046 ។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧- អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ២០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់ នួន ជា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ឯកសារ D158/5/3/15, ERN: 00366747-00366761។ *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម-១ ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ជួយសម្រួលឱ្យមានការផ្សព្វផ្សាយដល់ភាគីនូវរបាយការណ៍របស់ UN-OIOS ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ឯកសារ E65, ERN: 00327910-00327919 ។ *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ សេចក្តីសម្រេចលើសំណើរបស់មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម-១ សុំអោយអង្គជំនុំជម្រះសាលាដំបូងជួយសម្រួលការផ្សព្វផ្សាយដល់ភាគីនូវរបាយការណ៍របស់ UN-OIOS ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ E65/9, ERN: 00378404-00378411 ។

00572112



D388

## ១. មិនមានបទប្បញ្ញត្តិរបស់រដ្ឋធម្មនុញ្ញអនុញ្ញាតអោយមានអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ

២២. គួរកត់សម្គាល់ថា មិនមានត្រង់ចំណុចណាមួយក្នុងរដ្ឋធម្មនុញ្ញកម្ពុជាចែងអំពីនីតិវិធីសម្រាប់ដាក់បញ្ចូលច្បាប់ទំនៀមទម្លាប់អន្តរជាតិទៅក្នុងច្បាប់ជាតិនោះទេ[៥៨]។ នៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ រដ្ឋធម្មនុញ្ញពីរនៅជាធរមាននៅឡើយ[៥៩]។ រដ្ឋធម្មនុញ្ញមួយដែលត្រូវបានអនុម័តឡើងនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ នៅជាធរមាននៅទូទាំងអំឡុងពេលនៃរបបសាធារណៈរដ្ឋខ្មែរ (រហូតដល់ឆ្នាំ១៩៧៥)។ រដ្ឋធម្មនុញ្ញនៃរបបសាធារណៈរដ្ឋខ្មែរ គឺស្រដៀងគ្នាទៅនឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដោយរដ្ឋធម្មនុញ្ញនៃរបបសាធារណៈរដ្ឋខ្មែរគ្រាន់តែចែងនៅក្នុងមាត្រា ៣៨ ថា "ប្រធានាធិបតីនៃសាធារណៈរដ្ឋចុះហត្ថលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយឱ្យសច្ចាប័នលើឯកសារទាំងនេះ អាស្រ័យដោយការអនុម័តនៃសភា[៦០]។ មាត្រា ៧២ ហាមមិនឱ្យអនុវត្តច្បាប់ដោយប្រតិសកម្ម ទេ"វៀរលែងតែមានបទប្បញ្ញត្តិពិសេសដែលមានចែងជាក់លាក់ក្នុងច្បាប់នោះ"[៦១]។ នៅក្នុងរដ្ឋធម្មនុញ្ញនៃរបបសាធារណៈរដ្ឋខ្មែរ មិនមានបទប្បញ្ញត្តិណាមួយគាំទ្រដល់ការអះអាងថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាចត្រូវបានយកមកអនុវត្តផ្ទាល់នៅក្នុងតុលាការកម្ពុជា នាពេលនោះទេ។

២៣. រដ្ឋធម្មនុញ្ញបន្ទាប់មកទៀតត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ និងនៅជាធរមាននៅឡើយក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)[៦២]។ រដ្ឋធម្មនុញ្ញនេះរួមមានបទប្បញ្ញត្តិមួយចំនួនទាក់ទងនឹងក្របខ័ណ្ឌច្បាប់ដែលអាចអនុវត្តបាននាពេលនោះ។ មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦ គាំទ្រដល់ការអះអាងថា រាល់ទម្រង់នៃច្បាប់អន្តរជាតិ ដូចជា សន្ធិសញ្ញា ឬច្បាប់ទំនៀមទម្លាប់ អាចត្រូវបានអនុវត្តដោយ

---

[៥៨] *សូមមើល* JENNAR ។

[៥៩] JENNAR, ទំព័រ៥៧ និង៨១។

[៦០] *ដូចខាងលើដែរ*, ទំព័រ៥៤។

[៦១] *ដូចខាងលើដែរ*, ទំព័រ៥៨។

[៦២] *ដូចខាងលើដែរ*, ទំព័រ៨១។ ទោះបីជាគោលការណ៍នៃរដ្ឋធម្មនុញ្ញនេះត្រូវបានសម្រេចនៅដំណាច់ខែមេសា ឆ្នាំ១៩៧៥ ក៏ដោយ តែរដ្ឋធម្មនុញ្ញនេះត្រូវបានអនុម័តជាក់ស្តែង នៅក្នុងអំឡុងនៃកិច្ចប្រជុំក្រុមមេបញ្ជាការ នៅក្នុងទីក្រុងភ្នំពេញពីថ្ងៃទី១៥ ដល់ ១៩ ធ្នូ ឆ្នាំ១៩៧៥។

ផ្ទាល់នៅក្នុងតុលាការកម្ពុជា នាពេលនោះបានទេ។ មាត្រា៥ គ្រាន់តែចែងថា អំណាចធ្វើច្បាប់ ជាអំណាចរបស់សភាតំណាងប្រជាជន កម្មករ កសិករ និងពលករផ្សេងទៀតទាំងអស់។ មាត្រា៧ ចែងបញ្ជាក់ថា សភាតំណាងប្រជាជនមានភារៈសម្រេចច្បាប់ និងកំណត់មាគ៌ានយោបាយផ្សេងៗក្នុង និងក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ[៦៣]។

២៤. រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ (បានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៩) ដែលកំពុងតែនៅជាធរមាន គ្រាន់តែចែងថា ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា[៦៤]។ មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គាំទ្រដល់ការអះអាងថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចត្រូវបានយកមកអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជា នាពេលនេះបានទេ រួមទាំង អ.វ.ត.ក ផងដែរ។

## ២. មិនមានច្បាប់ដាក់អោយអនុវត្តសម្រាប់ច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ

២៥. រដ្ឋសភានៃប្រទេសកម្ពុជាមិនបានអនុម័តច្បាប់ណាមួយ ដែលមានការយោងជាក់លាក់ទៅនឹងវិធានណាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ។ ក្នុងរយៈកាល ១៧ ឆ្នាំកន្លងមកនេះ រដ្ឋសភានៃប្រទេសកម្ពុជាបានអនុម័តតែសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិតែប៉ុណ្ណោះ ដូចជា ច្បាប់ស្តីពីការសម្រេចដាក់ប្រទេសកម្ពុជាទៅជាសមាជិកនៃពិធីសារក្យូតូ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលត្រូវបានអនុម័តដោយរដ្ឋសភា កាលពីថ្ងៃ ទី២៦ ខែតុលា ឆ្នាំ២០០៦[៦៥]។

## ៣. តុលាការកម្ពុជាមិនអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ

---

[៦៣] ដូចយោងខាងលើ ទំព័រ៦៨។

[៦៤] *សូមមើល* មាត្រា២៦ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មក្នុងខែមីនា ឆ្នាំ១៩៩៩។

[៦៥] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក//កសចស (អបជ៣៥) បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កចសច ស្តីពីការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលគេស្គាល់ថាជាសហឧក្រិដ្ឋកម្មរួមៈ ឯកសារឧបសម្ព័ន្ធ ក ៖ សេចក្តីសង្ខេបទៅលើសារណានានាអំពី JCE របស់ក្រុមមេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ២២ មករា ២០១០ ឯកសារលេខ D97/14/5.2, ERN: 00440434-00440481 លេខយោង ២៤១។

D388

## ដោយផ្ទាល់ទានទេ

២៦. មិនមានរឿងក្តី ឬសេចក្តីសម្រេចណាមួយរបស់កម្ពុជា ដែលដោះស្រាយបញ្ហាដ៏ស្មុគ្រស្មាញនៃការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់នៅក្នុងតុលាការកម្ពុជាទេ។ ប៉ុន្តែ ការណែនាំគឺជាការដែលមិនអាចប្រកែកបានដែលថា ប្រព័ន្ធច្បាប់កម្ពុជាឆ្លុះបញ្ចាំងពីប្រព័ន្ធច្បាប់បារាំង ហើយដូច្នោះ វិធីសាស្ត្ររបស់តុលាការបារាំងចំពោះបញ្ហានេះ គឺជាការជាប់ទងគ្នាយ៉ាងសំខាន់បំផុត។ ដោយសារថា ប្រទេសបារាំងបានបដិសេធមិនអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់នៅក្នុងតុលាការជាតិរបស់ខ្លួន[៦៦] នោះវាសមហេតុសមផលណាស់ដែលកម្ពុជាពិតជាបដិសេធមិនអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងតុលាការជាតិរបស់ខ្លួនដូចគ្នានេះដែរ លើកលែងតែមានការចែងផ្សេងពីនេះក្នុងគោលបំណងឲ្យច្បាប់របស់ខ្លួនមានភាពច្បាស់លាស់។

២៧. នៅពេលដែលច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានគេយកមកសំអាងនៅក្នុងតុលាការជាតិនោះតុលាការមានកាតព្វកិច្ចពិចារណាថាតើ និងនៅក្នុងកាលៈទេសៈណាដែលប្រព័ន្ធច្បាប់ជាតិត្រូវបានអនុញ្ញាត ឬមានកាតព្វកិច្ចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ការមិនមានសេចក្តីណែនាំជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ឬយុត្តិសាស្ត្រជាតិរបស់ខ្លួន តុលាការជាតិមិនមានអំណាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទេ[៦៧]។

២៨. ការអនុវត្តជាក់ស្តែងរបស់តុលាការកម្ពុជា ក្នុងការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់ត្រូវបានអ្នកនិពន្ធមួយរូបសង្ខេបសេចក្តីថា "បើទោះជាមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ហាក់ដូចជាបានដាក់បញ្ចូលបទដ្ឋានសិទ្ធិមនុស្សទៅក្នុងច្បាប់កម្ពុជាដោយផ្ទាល់ រដ្ឋធម្មនុញ្ញដដែលនេះមិនបានប្រកាស ថាតើប្រទេសកម្ពុជាអនុវត្តតាមប្រព័ន្ធឯកនិយម ឬប្រព័ន្ធទ្វិកនិយមនោះទេ។ ដោយការមិនមានច្បាប់ចង្អុលបង្ហាញអំពីការអនុវត្តបែបនេះ តុលាការបដិសេធការអះអាងទាំង

---

[៦៦] *សូមមើល* កថាខណ្ឌ១៤ និង១៥ ខាងលើ។

[៦៧] CASSESE, ទំព័រ៣០៣។ "តាមធម្មតា តុលាការជាតិមិនធានារ៉ាប់រងទៅលើដំណើរការនីតិវិធីចំពោះបទល្មើសអន្តរជាតិនោះទេ ដោយគ្រាន់តែយោងទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិប៉ុណ្ណោះទេ មានន័យថា ចំពោះករណីដែលបទល្មើសត្រូវបានចែងតែនៅក្នុងច្បាប់នេះតែប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ តុលាការជាតិតម្រូវឲ្យមានច្បាប់ជាតិដែលកំណត់និយមន័យអំពីបទល្មើស និងផ្តល់យុត្តាធិការដល់តុលាការជាតិទៅលើបទល្មើសនោះ ឬប្រសិនបើរដ្ឋមួយបានផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាស្តីពីបញ្ហានោះ នោះគឺជាការអនុម័តច្បាប់ដាក់អោយអនុវត្ត ដែលបង្កលក្ខណៈឲ្យតុលាការអនុវត្តបទប្បញ្ញត្តិសន្ធិសញ្ញាពាក់ព័ន្ធបានយ៉ាងពេញលេញ។ (មានគូសបញ្ជាក់បន្ថែមនៅក្នុងច្បាប់ដើម)។

ឡាយ ដែលបានយោងទៅលើច្បាប់អន្តរជាតិដោយផ្ទាល់ ឬសូម្បីតែយោងទៅលើរដ្ឋធម្មនុញ្ញក៏ដោយ[៦៨]។ អាស្រ័យហេតុនេះ ដោយការមិនមានច្បាប់ចង្អុលបង្ហាញអំពីការអនុវត្តបែបនេះ តុលាការកម្ពុជា ដូចជា អ.វ.ត.ក ជាដើម នឹងបដិសេធមិនទទួលយកការអះអាងទាំងឡាយដែលសំអាងទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

## គ. ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចអនុវត្តនៅ អ.វ.ត.ក បានទេ

២៩. អង្គបុរេជំនុំជម្រះបានទទួលយកលក្ខខណ្ឌ ដែលបានចែងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) ដែលនៅក្នុងលក្ខខណ្ឌនោះ "អង្គជំនុំជម្រះតុលាការកំពូល ICTY បានកំណត់បុរេលក្ខខណ្ឌចំនួនបួនដែលទម្រង់ណាមួយនៃការទទួលខុសត្រូវ ត្រូវតែបានបំពេញដើម្បីឲ្យទម្រង់នោះស្ថិតនៅក្នុងយុត្តាធិការ[របស់ខ្លួន]"[៦៩]។ ដូចដែលបានពិភាក្សាខាងក្រោម ការអនុវត្តលក្ខខណ្ឌទាំងនេះចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនមានលក្ខខណ្ឌណាមួយត្រូវបានបំពេញនោះឡើយ៖

### ១. ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អវតក រំលោភទៅលើគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់បញ្ញត្តិ

៣០. អង្គបុរេជំនុំជ្រះបានយល់ឃើញថា "លក្ខខណ្ឌយ៉ាងច្បាស់ក្នុងមាត្រា២នៃច្បាប់ស្តីពីការបង្កើត អវតក... អាចគ្រាន់តែនាំឲ្យមានការសន្និដ្ឋានដែលថា អវតក មានយុត្តាធិការដើម្បីអនុវត្ត...ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអំឡុងពេលវេលាពាក់ព័ន្ធ"[៧០] ។ មាត្រា ២ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ចែងថា អវតក ត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិប

---

[៦៨] Suzannah Linton, *Putting Cambodia's Extraordinary Chambers into Context* (ការដាក់អង្គជំនុំជម្រះវិសាមញ្ញនៃប្រទេសកម្ពុជាទៅក្នុងបរិបទ), 11 SING. Y.B. INT'L L. 195, 203-04 (2007) (មានគូសបញ្ជាក់បន្ថែម)។

[៦៩] i) ច្បាស់ ឬមិនច្បាស់ វាត្រូវតែមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អវតក ii) វាពិតជាមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាពាក់ព័ន្ធ iii) ច្បាប់ ... ត្រូវតែអាចស្វែងរកបានគ្រប់គ្រាន់អំពីសម្រាប់បុគ្គលដែលបានប្រព្រឹត្តដែលមានចែងក្នុងច្បាប់នោះ iv) បុគ្គលនេះប្រាកដជាអាចប្រមើលមើលដឹងថា គាត់នឹងត្រូវគេតម្រូវឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះទង្វើរបស់គាត់ ប្រសិនជាគាត់ត្រូវចាប់ខ្លួន ។ សាលដីកា JCE , នៅត្រង់កថាខណ្ឌទី៤៣ ។

[៧០] សាលដីកា JCE , នៅត្រង់កថាខណ្ឌទី៤៨ ។

តេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើ...ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ...” ។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថាច្បាប់បង្កើត អវតក អាចយកមកអនុវត្តដោយមានអានុភាពប្រតិសកម្មនូវច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន ។ ការយល់ឃើញនេះរំលោភទៅលើគោលការណ៍ គ្មានបទល្មើស និងគ្មានទោសបើគ្មានច្បាប់ចែង (*nullum crimen, nulla poena sine lege*) ។ គោលការណ៍ *nullum crimen, nulla poena sine lege*[៧១] លើកឡើងថាគ្មានជនណាម្នាក់អាចត្រូវបានកាត់ទោសបានឡើយ លុះត្រាអំពើដែលបានប្រព្រឹត្តនោះមានចែងនៅក្នុងច្បាប់ថាជាបទល្មើសនិងលុះត្រាតែច្បាប់បានចែងពីការដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋនោះ នៅខណៈពេលប្រព្រឹត្តបទល្មើសនោះ។ គោលការណ៍នេះមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ (ICCPR) ដែល អវតក ត្រូវតែគោរពបទដ្ឋានទាំងនេះឲ្យបានពេញលេញ[៧២] ។

៣១. មាត្រា១៥(១) នៃ ICCPR ចែងថា “នៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ គ្មានជនណាម្នាក់មានទោសពីបទល្មើសព្រហ្មទណ្ឌដោយសារតែការប្រព្រឹត្ត ឬការខកខាន ដែលមិនមែនជាបទល្មើស

---

[៧១] ជាពិសេស គោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* នៅក្នុងប្រទេសដែលអនុវត្តច្បាប់ស៊ីវិលឡូ បានបញ្ជាក់យ៉ាងច្បាស់នូវគោលគំនិតបួន i) បទល្មើសព្រហ្មទណ្ឌត្រូវតែមានចែងតែនៅក្នុងច្បាប់ជាលាយក្ខណ្ឌអក្សរ (“*nullum crimien sine lege scripta*”), ii) បទល្មើសព្រហ្មទណ្ឌត្រូវតែមានចែងតែនៅក្នុងច្បាប់ជាក់លាក់ (“*nullum crimen sine lege stricta*”), iii) បទល្មើសព្រហ្មទណ្ឌត្រូវតែមានចែងតែនៅក្នុងច្បាប់ពីមុន (”*nullum crimen sine proevia lege*”) និង iv) បទល្មើសព្រហ្មទណ្ឌ មិនត្រូវបកស្រាយតាមន័យប្រហាក់ប្រហែលឡើយ។ CASSES ១៤១ ដល់១៤២។

[៧២] យោងតាមមាត្រាទី៣១ នៃច្បាប់ធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ដែលបានធ្វើវិសោធន៍កម្មកាលពីថ្ងៃទី៤ខែមិនា ចែងថា “ ព្រះរាជាណាចក្រកម្ពុជា <u>ទទួលស្គាល់ និងគោរព</u>សិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងកុមារ ។ (គូសបញ្ជាក់បន្ថែម)។ យោងតាមមាត្រា៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អវតក ចែងថា អង្គជំនុំជម្រះត្រូវតែអនុវត្តយុត្តាធិការរបស់ពួកគេឲ្យស្របទៅនឹងបទដ្ឋានយុត្តិធម៌អន្តរជាតិ និងឲ្យស្របតាមច្បាប់ដូចដែលបានចែងនៅក្នុងមាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៩៦ ស្តីពិសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ ”។ យោងតាមមាត្រា១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជាទៅលើបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លើកឡើងថា “សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៩៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពទូទាំងដំណើរការនៃការជំនុំជម្រះក្តី” ។

ព្រហ្មទណ្ឌនៅពេលដែលប្រព្រឹត្តបទល្មើសនោះ”[៧៣]។ ទាក់ទងនឹងច្បាប់ជាតិ ដូចដែលបានពន្យល់ខាងលើ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនបានបង្កើតជាផ្នែកមួយនៃច្បាប់ជាតិឡើយ នៅក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អវតក[៧៤]។

៣២. សេចក្តីណែនាំទាក់ទងនឹងនិយមន័យរបស់ប្រយោគ “ឬក៏ច្បាប់អន្តរជាតិ” អាចរកឃើញនៅក្នុងយុត្តិសាស្ត្រនៃតុលាការអឺរ៉ុបសិទ្ធិមនុស្ស ។ នៅក្នុងរឿងក្តី K.-H.W តទល់នឹងប្រទេសអាឡឺម៉ង់[៧៥] តុលាការអឺរ៉ុបសិទ្ធិមនុស្សបានពិចារណាមាត្រា៧ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ដែលឆ្លុះបញ្ចាំងពីមាត្រា១៥ នៃ ICCPR[៧៦] ។ ការអត្ថាធិប្បាយទាក់ទងនឹងរឿងក្តី K.-H.W *តទល់*នឹងប្រទេសអាឡឺម៉ង់លើកឡើងថា ការដែលថាតុលាការអឺរ៉ុបសិទ្ធិមនុស្ស បានប្រកាន់ភ្ជាប់នូវប្រយោគ “ឬច្បាប់អន្តរជាតិ” គឺផ្អែកទៅលើថាតើបុគ្គលដែលពាក់ព័ន្ធនោះអាចដឹងដោយសមហេតុផលថា បទល្មើសដែលខ្លួនបានប្រព្រឹត្តិនោះ ត្រូវបានហាមឃាត់ និងត្រូវបានដាក់ទណ្ឌកម្មនៅក្នុងប្រព័ន្ធច្បាប់ដែលពាក់ព័ន្ធនៅពេលវេលាហ្នឹង តាមរយៈច្បាប់ជាតិ ឬតាមរយៈច្បាប់អន្តរជាតិដែលអាចអនុវត្តដោយផ្ទាល់ដែលមានអានុភាពផ្ទៃក្នុងដែរឬអត់”[៧៧]។ ដូច្នេះ មានតែការដឹងឮសមហេតុផលអំពីបទល្មើសដែលទាក់ទងនឹងច្បាប់អន្តរជាតិដែលត្រូវបានហាមឃាត់ និងដាក់ទណ្ឌកម្មដោយតុលាការកម្ពុជានៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ប៉ុណ្ណោះ ទើបអនុញ្ញាតឱ្យមានការអនុវត្តបទល្មើសនោះចំពោះជនត្រូវចោទ ។

---

[៧៣] មាត្រា១១(២) នៃសេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្ស មានបទបញ្ញត្តិស្រដៀងគ្នានេះ “នៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិគ្មានជនណាម្នាក់មានទោសពីបទល្មើសព្រហ្មទណ្ឌដោយសារការប្រព្រឹត្ត ឬការខកខាន ដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌឡើយ នៅពេលដែលបទល្មើសនេះត្រូវបានប្រព្រឹត្ត” ។

[៧៤] សូមមើលផ្នែក III (ខ) ខាងលើ។

[៧៥] ករណី K.-H.W *តទល់នឹង* ប្រទេសអាឡឺម៉ង់ (បណ្តឹងលេខ 37201/97)។ សាលក្រម ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០១ (“K.-H.W តទល់នឹងប្រទេសអាឡឺម៉ង់” )។

[៧៦] មាត្រាទី៧(១) នៃសិទ្ធិមនុស្សអឺរ៉ុប ចែងមួយផ្នែកថា “នៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ គ្មានជនណាម្នាក់មានទោសពីបទល្មើសព្រហ្មទណ្ឌដោយសារការប្រព្រឹត្ត ឬការខកខាន ដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌឡើយនៅពេលដែលបទល្មើសនេះត្រូវបានប្រព្រឹត្ត”។

[៧៧] PIETER VAN DIJK, FRIED VAN HOOF, ARJEN VAN RIJN & LEO ZWAAK, THEORY AND PRACTICE OF THE EUROPEAN CONVENTION ON HUMAN RIGHTS 660 (4th ed. Intersentia 2006); អត្ថាធិប្បាយលើ *K. -H. W.* ទល់នឹងប្រទេសអាឡឺម៉ង់, កថាខណ្ឌទី៩១ ដល់៩៣។

៣៣. ជាងនេះទៅទៀត គោលការណ៍ *nullum crimen, nulla poena sine lege* លើកឡើងថា ទណ្ឌកម្មត្រូវតែចែងដោយច្បាប់ ។ ពុំមានបទល្មើសព្រហ្មទណ្ឌណាមួយដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បើសិនអាចត្រូវបានរកឃើញថាវាមានអត្ថិភាព មានការដាក់ទណ្ឌកម្មឱ្យស្របទៅនឹងទំហំនៃបទល្មើសឡើយ ។ ដូច្នេះបទល្មើសព្រហ្មទណ្ឌណាមួយដែលមានចែងនៅក្នុងច្បាប់ទំនៀងទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលអនុវត្តនៅ អវតក នឹងរំលោភទៅលើគោលការណ៍ *nullum crimen, nulla poena sine lege* ព្រោះគ្មានទណ្ឌកម្មណាមួយបានកើតឡើងចំពោះបទឧក្រិដ្ឋបែបនេះឡើយ ។

## ២. ឧក្រិដ្ឋកម្ម ឬ ទម្រង់នៃការទទួលខុសត្រូវទាំងឡាយណាដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាដែលពាក់ព័ន្ធ គឺមិនពាក់ព័ន្ធទេ ដោយសារតែច្បាប់កម្ពុជាមិនបានចែងពីការអនុវត្តដោយផ្ទាល់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ

៣៤. ភាពខុសគ្នាជាសារវ័ន្តរវាង អវតក និង ICTY ដែលជាតុលាការអន្តរជាតិមួយបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិគឺថា ICTY មានសិទ្ធិអនុវត្តដោយផ្ទាល់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៧៨] ។ វាពិតជាសមហេតុផលទាំងស្រុង ។ ICTY មិនមែនជាតុលាការក្នុងស្រុករបស់ប្រទេសយូហ្គោស្លាវី ហើយក៏មិនចាំបាច់ជ្រើសរើសរវាងច្បាប់យូហ្គោស្លាវី និងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ ។ តុលាការនេះមានកាតព្វកិច្ចតែមួយគត់គឺពិចារណាលើច្បាប់ក្នុងស្រុករបស់អតីតយូហ្គោស្លាវី ទាក់ទងនឹងការកំណត់ទោសប៉ុណ្ណោះ[៧៩] ។ ផ្ទុយមកវិញ អវតក ត្រូវបានបង្កើត

---

[៧៨] ជាទស្សនៈរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ការអនុវត្តគោលការណ៍<u>គ្មានបទល្មើសបើគ្មានច្បាប់ចែង</u> (Nullum crimen sine lege) តម្រូវថាតុលាការអន្តរជាតិ ត្រូវអនុវត្តវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលច្បាស់លាស់ជាក់ស្តែងជាផ្នែកមួយច្បាប់ទំនៀមទម្លាប់..."។ កថាខណ្ឌទី ៣៤ នៃរបាយការណ៍របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៩៣ ដោយអនុលោមទៅតាមកថាខណ្ឌទី ២ នៃសេចក្តីសម្រេចលេខ ៨០៨(១៩៩៣) របស់ក្រុមប្រឹក្សាសន្តិសុខ, ឯកសារ UN លេខ S/25704, (បញ្ជាក់នៅអត្ថបទដើម) ។ សូមមើលផងដែររឿងក្តី រដ្ឋអាជ្ញាតទល់ជាមួយ *Tadić*, IT-94-01 កថាខណ្ឌទី ៦០ នៃសេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្តីពីយុត្តាធិការ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៥ ដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា "ខុសពីរដ្ឋជាភាគីនៃសន្ធិសញ្ញា តុលាការអន្តរជាតិមិនត្រូវបានស្នើសុំឱ្យអនុវត្តច្បាប់អនុសញ្ញា (conventional law) តែតុលាការនេះទទួលបានអាណត្តិដើម្បីអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ" ។

[៧៩] សូមមើលវិធាន ១០១(ខ)(iii) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ ICTY ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨, IT/32/Re.41 ។

ឡើងក្នុងរចនាសម្ព័ន្ធតុលាការ ដែលមានស្រាប់នៃប្រព័ន្ធច្បាប់ជាតិរបស់ប្រទេសកម្ពុជា[៨០] តុលាការនេះ អាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ប្រសិនបើអនុញ្ញាត ឬ តម្រូវដោយច្បាប់កម្ពុជាតែប៉ុណ្ណោះ ។

## ៣. ឧក្រិដ្ឋកម្ម ឬ ទម្រង់នៃការទទួលខុសត្រូវទាំងឡាយណាដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺមិនអាចស្វែងរកបានគ្រប់គ្រាន់នៅពេលវេលាដែលពាក់ព័ន្ធ

៣៥. អង្គជំនុំជម្រះយល់ឃើញថា "ចំពោះភាពអាចរកបាន ក៏រួមបញ្ចូលសំអាងច្បាប់ទាំងឡាយណាដែលផ្អែកលើទំនៀមទម្លាប់ដែរ"[៨១] ដោយពុំបានផ្តល់ការវិភាគណាមួយថាហេតុអ្វីបានជាមានការយល់ឃើញខាងលើនេះឡើយ ។ សាស្ត្រាចារ្យ Ferdinandusse បានលើកឡើងនូវបញ្ហាគន្លឹះនៃភាពអាចស្វែងរកបាននៃបទល្មើស ដែលផ្អែកលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ "ដោយសារតែច្បាប់ទំនៀមទម្លាប់អន្តរជាតិជាប្រភពមិនសរសេរជាលាយលក្ខណ៍អក្សរ ដូច្នេះធម្មតាច្បាប់ទំនៀមទម្លាប់អន្តរជាតិនេះមិនបានបោះពុម្ពផ្សាយអោយដូចជាសន្ធិសញ្ញា និង ច្បាប់ឡើយ។ អាស្រ័យហេតុនេះ ច្បាប់ទំនៀមទម្លាប់អន្តរជាតិនេះកម្រនឹងស្វែងរកបានដោយសាធារណៈជនណាស់"[៨២] ។ ភាពអាចរកបាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺជួបឧបសគ្គភ្លាមៗ ដោយសារតែចរិតធម្មជាតិមិនសរសេរជាលាយលក្ខណ៍អក្សររបស់ច្បាប់នេះ ។

## ៤. ឧក្រិដ្ឋកម្ម ឬ ទម្រង់នៃការទទួលខុសត្រូវទាំងឡាយណាដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺមិនអាចប្រមើលដឹងបានគ្រប់គ្រាន់នៅពេលវេលាដែលពាក់ព័ន្ធ

៣៦. ក្រមព្រហ្មទណ្ឌកម្ពុជាដែលមានប្រសិទ្ធិភាពអនុវត្តនៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ គឺជាក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ។ អវតក ទទួលស្គាល់ចំណុចនេះ[៨៣] ។ នៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ គឺជាក្រមព្រហ្មទណ្ឌតែមួយគត់ដែលអនុវត្តចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៅកម្ពុជា ។ ហេតុនេះ ជនត្រូវចោទមិនអាចប្រមើលដឹងថាខ្លួនត្រូវទទួលខុសត្រូវ

---

[៨០] សូមមើលផ្នែក III ខាងលើ ។

[៨១] សាលដីកា JCE នៅត្រង់កថាខណ្ឌទី ៤៥ ។

[៨២] FERDINANDUSSE, នៅត្រង់ទំព័រទី ៤៥ ។ ។

[៨៣] សូមមើលមាត្រា ៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ។

ផ្នែកព្រហ្មទណ្ឌ ដោយច្បាប់ព្រហ្មទណ្ឌណាផ្សេងទៀតនៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ឡើយ។ ប៉ុន្តែ ជនត្រូវចោទអាចប្រមើលដឹងថាច្បាប់ព្រហ្មទណ្ឌមិនអាចអនុវត្តជាប្រតិសកម្មបានទេ។ មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចែងយ៉ាងច្បាស់ថា "ក្រមព្រហ្មទណ្ឌគ្មានអានុភាពជាប្រតិសកម្មទេ ។ បទល្មើសណាបានប្រព្រឹត្តមុនបទបញ្ញត្តិរបស់ច្បាប់ បទល្មើសនោះមិនអាចត្រូវនិគ្រោះដោយទោសរបស់ច្បាប់ ដែលទើបនឹងបញ្ញត្តិថ្មីៗនេះបានទេ"[៨៤]។ នៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ បុគ្គលម្នាក់អាចនឹងត្រូវបានគេប្រាប់យ៉ាងច្បាស់ថា ក្រមព្រហ្មទណ្ឌមិនអនុវត្តជាប្រតិសកម្មបានទេ ។ ជនត្រូវចោទមិនអាចប្រមើលដឹងពីការអនុវត្តជាប្រតិសកម្មនៃច្បាប់បានទេ ។

៣៧. នៅប្រទេសកម្ពុជាចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ពុំមានបទបញ្ញត្តិច្បាប់ជាតិ ឬ បទបញ្ញត្តិច្បាប់អន្តរជាតិអនុវត្តដោយផ្ទាល់ ដែលមានអានុភាពមកអនុវត្តថ្នាក់ជាតិ ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើល្មើសនានា ដែលមានចែងនៅក្នុងច្បាប់បង្កើត អវតក និងទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលមាននៅក្នុងច្បាប់នេះទេ[៨៥]។ ហេតុដូច្នេះ ជនត្រូវចោទមិនអាចប្រមើលដឹងឲ្យបានគ្រប់គ្រាន់ថាច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាចអនុវត្តប្រឆាំងនឹងពួកគេនោះទេ ។ តាមពិតអង្គបុរេជំនុំជម្រះដឹងថាបទបញ្ញត្តិនានានៅក្នុងច្បាប់កម្ពុជា គឺចាំបាច់ផ្តល់ការជូនដំណឹងពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលនៅជាធរមាននៅពេលវេលាដែលពាក់ព័ន្ធ[៨៦] ។

៣៨. ការវិវឌ្ឍន៍ជាបន្តបន្ទាប់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ព្រមជាមួយឋានៈរបស់វាដែលស្ថិតជាបញ្ហានេះ ធ្វើឲ្យគេរាល់គ្នាពិបាកយល់ថាអ្វីទៅជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលវេលាចាំបាច់[៨៧]។ តាមពិតបញ្ហានេះត្រូវបានលើកឡើងនៅក្នុងសាលដីកា JCE ដែលក្នុងនោះ អង្គបុរេជំនុំជម្រះយល់ឃើញយ៉ាងត្រឹមត្រូវថា JCE III មិនបង្កើតជាទម្រង់មួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះ

---

[៨៤] អន្លបទបកប្រែក្រៅផ្លូវការពីភាសាបារាំង ។

[៨៥] សូមមើលផ្នែក III(ខ) ខាងលើ ។

[៨៦] "អង្គបុរេជំនុំជម្រះមិនអាចកំណត់បទបញ្ញត្តិណាមួយនៅក្នុងច្បាប់កម្ពុជា ដែលនៅជាធរមាននៅពេលវេលាដែលពាក់ព័ន្ធ ដែលអាចផ្តល់ការជូនដំណឹងដល់ជនត្រូវចោទថា ទម្រង់លាតសន្ធឹង(ទម្រង់ទីបី)នៃការទទួលខុសត្រូវនេះ គឺអាចផ្តន្ទាទោសបានដែរនោះឡើយ" សាលដីកា JCE នៅត្រង់កថាខណ្ឌទី ៨៧ ។

[៨៧] "តម្រូវការដើម្បីធ្វើការសម្រួលនៅក្នុងការតាក់តែងច្បាប់អន្តរជាតិ តែងតែហាមឃាត់ការកំណត់និយមន័យបទល្មើសឲ្យបានច្បាស់ ងាយស្រួលយល់។ ជាផលវិបាក បទល្មើសអន្តរជាតិជាច្រើនកង្វះការពិពណ៌នាលំអិតអំពីទង្វើប្រព្រឹត្តដែលហាមឃាត់ការផ្តន្ទាទោសអាចអនុវត្តទៅលើការប្រព្រឹត្តនោះ ហើយសូម្បីតែការយោងទៅលើការកំណត់បទល្មើសថា ជាបទឧក្រិដ្ឋ ឬ ជាការចោទប្រកាន់ដែលគេចង់បាន" ។ FERDINANDUSSE, at 239.

ឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ទេ[៨៨] ។

## ឃ. ទោះបីជាបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិបានបំពេញលក្ខខណ្ឌដាច់ខាត (jus cogens) ក៏ដោយ ក៏វាមិនប៉ះពាល់ដល់ការមិនអនុវត្តនៅ អ.វ.ត.ក នោះដែរ

៣៩. បទដ្ឋានដាច់ខាត *(jus cogens)* ត្រូវបានកំណត់និយមន័យថាជា "វិធាននៃច្បាប់ទំនៀមទម្លាប់ដែលមិនអាចជំនួសដោយសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងបានទេ ប៉ុន្តែ អាចជំនួសបានដោយការបង្កើតវិធានទំនៀមទម្លាប់បន្តបន្ទាប់ ដែលមានភាពផ្ទុយគ្នាពីនេះ[៨៩]។ មិនមានបទដ្ឋានអាជ្ញាបញ្ជា *(peremptory norm)* ណាតម្រូវឱ្យរដ្ឋត្រូវតែធ្វើការផ្តន្ទាដោយអនុវត្តតាមបទដ្ឋាន *jus cogens* នោះទេ។ ផ្ទុយទៅវិញ រដ្ឋទាំងឡាយមិនអាចសំអាងទៅលើចរិតលក្ខណៈ *jus cogens* នៃបទល្មើសមួយ ដើម្បីអនុវត្តយុត្តាធិការលើកបទល្មើសបានទេ ប្រសិនបើប្រព័ន្ធច្បាប់ជាតិរបស់ខ្លួនមិនមានចែងពីយុត្តាធិការនេះទេ[៩០]។ ដូចដែលបានពន្យល់ខាងលើរួចមកហើយ ប្រព័ន្ធច្បាប់កម្ពុជាមិនបានចែងពីយុត្តាធិការនេះទេ។

៤០. សូម្បីតែឧបមាថា រដ្ឋនីមួយៗមានកាតព្វកិច្ចធ្វើការផ្តន្ទាទោសដោយអនុវត្តតាមបទដ្ឋាន *jus cogens* នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏កាតព្វកិច្ចនេះមិនធ្លាក់ទៅលើ អ.វ.ត.ក នោះដែរ ប៉ុន្តែកាតព្វកិច្ចនេះធ្លាក់ទៅលើរដ្ឋាភិបាលកម្ពុជាទៅវិញទេ។ នៅក្នុងសង្គមប្រជាធិបតេយ្យ "បទល្មើសព្រហ្មទណ្ឌត្រូវបានកំណត់យ៉ាងច្បាស់ដោយស្ថាប័ននីតិបញ្ញត្តិ។ តុលាការខ្លួនឯងមិនអាចសម្រេចអំពីអត្ថិភាពនៃបទល្មើសមួយថ្មី *(de novo)* ដែលមិនមានចែងក្នុងច្បាប់ដែលបានប្រកាស

---

[88] ដូចយោងខាងលើ នៅត្រង់កថាខណ្ឌទី ៨៣ ។

[៨៩] BROWNLIE ទំព័រទី៥១០។

[៩០] នៅក្នុងរឿងក្តី *Pinochet* ចៅក្រម Millet មានបំណងប្រើប្រាស់ទឡ្ហីករណ៍ថា រដ្ឋមានយុត្តាធិការជាសកលទៅលើការរំលោភបទដ្ឋាន *jus cogens* ។ ប៉ុន្តែ គំនិតយល់ឃើញរបស់គាត់មិនត្រូវបានចៅក្រមនៅតុលាការជាន់ខ្ពស់ដទៃទៀតទទួលយកទេ។ ចៅក្រម Hope បានប្រកាសថា៖ "មុននឹងផ្នែកទី១៣៤ នៃច្បាប់ស្តីពីយុត្តិធម៌ព្រហ្មទណ្ឌឆ្នាំ១៩៨៨ ចូលជាធរមាន...មិនមានមូលដ្ឋានណាមួយដែលថា [*Pinochet*] អាចត្រូវបានកាត់ទោសហួសដែនសមត្ថកិច្ចរបស់ប្រទេសនេះបាន តាមរយៈនេះ តម្រូវឱ្យប្រព័ន្ធច្បាប់ជាតិអង់គ្លេសមានចែងអំពីយុត្តាធិការ សូម្បីតែចំពោះការរំលោភលើបទដ្ឋាន *jus cogens* ក៏ដោយ។ *សូមមើល Pinochet* ត្រង់ទំព័រ២៣៧ និង២៧៥។

D 388

ឱ្យប្រើដោយស្ថាប័ននីតិប្រតិបត្តិបានទេ[៩១]។ ដូច្នេះ កាតព្វកិច្ចច្បាប់ទំនៀមទម្លាប់អន្តរជាតិតាមបែបសន្ធិតដើម្បីអនុវត្ត *បទដ្ឋាន jus cogens* គឺជាបន្ទុករបស់ប្រទេសកម្ពុជាក្នុងនាមជារដ្ឋមួយ មិនមែន អ.វ.ត.ក នោះទេ។

**អាស្រ័យដោយ** មូលហេតុដូចដែលបានលើកឡើងខាងលើនេះ មេធាវីការពារក្តីសូមស្នើដោយក្តីគោរពឱ្យសហចៅក្រមស៊ើបអង្កេត **បដិសេធ** ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់ នៅចំពោះមុខ អ.វ.ត.ក។

សូមលោកសហចៅក្រមទទួលយកសារណានេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២២** ខែកក្កដា ឆ្នាំ២០១០

សហមេធាវីរបស់លោក **អៀង សារី**

ទេសនាមិ AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** **Michael G. KARNAVAS**

---

[៩១] Ilias Bantekas, [Reflections on Some Sources and Methods of International Criminal and Humanitarian Law (ការផ្តុះបញ្ចាំងទៅលើប្រភព និងវិធីសាស្ត្រខ្លះៗនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ), 6 INT'L CRIM. L. REV. 121, 125 (2006)] ។